**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លក្ខខណ្ឌទូទៅ និង ការអនុវត្តសម្រាប់ការទិញទំនិញតាមប្រព័ន្ធអនឡាញនៃព្រឹត្តិការណ៍

"1st Phnom Penh Shopping Festival"

ក្រុមហ៊ុន **KHB Events** ដែលជាអ្នករៀបចំព្រឹត្តិការណ៍ **1st Phnom Penh Shopping Festival** បានអភិវឌ្ឍព្រឹត្តិការណ៍ពិព័រណ៌នេះជាទម្រង់ពិព័រណ៌ Online/Offline ដែលដំណើរការរយៈពេល៨ថ្ងៃ ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥នេះ។ តាមរយៈទម្រង់ពិព័រណ៌បែបថ្មីនេះ លោក-លោកស្រីអាចចាប់ផ្តើមទិញទំនិញរាប់រយមុខពីក្រុមហ៊ុនដែលបានចូលរួមតាំងពិព័រណ៌ក្នុងព្រឹត្តិការណ៍ **1st Phnom Penh Shopping Festival** ពីផ្សារអនឡាញ (shopping.khbevents.com) ចាប់ពីថ្ងៃទី ១៩ ដល់ ២៧ ខែកក្កដា ឆ្នាំ២០២៥ ហើយអាចមកយកទំនិញនៅក្នុងកម្មវិធីពិព័រណ៌ដោយផ្ទាល់ចាប់ពីថ្ងៃទី ២៦ ដល់ ២៧ ខែកក្កដា ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលពិព័រណ៌ និង សន្និបាតកោះពេជ្រ។

## I. ជំហ៊ាននៃការទិញទំនិញតាមផ្សារអនឡាញ (shopping.khbevents.com)

១.១ ដើម្បីអាចទិញទំនិញពីផ្សារអនឡាញរបស់ **1st Phnom Penh Shopping Festival** លោក-លោកស្រី អាចអនុវត្តតាមជំហ៊ានងាយៗ ដូចខាងក្រោម៖

**ដំណាក់កាលទី១៖** លោក-លោកស្រី នឹងឃើញការផ្សព្វផ្សាយពីផលិតផលនានាដែលមានការបញ្ចុះតម្លៃពិសេស ដែលចូលរួមតាំងពិព័រណ៌នៅក្នុង **1st Phnom Penh Shopping Festival** តាមបណ្តាញអនឡាញ ឬ លោក-លោកស្រី អាចចូលទៅកាន់ផ្សារអនឡាញដោយផ្ទាល់តាមរយៈគេហទំព័រ **(shopping.khbevents.com)** ចាប់ពីថ្ងៃទី១៩ ដល់២៧ ខែកក្កដា ២០២៥។

**ដំណាក់កាលទី២៖** បន្ទាប់មក លោក-លោកស្រី អាចចុចលើដំណភ្ជាប់លើផលិតផលដែលចង់ទិញ **(Order now)** រួចចូលទៅក្នុងផ្សារអនឡាញ ដើម្បីស្វែងរកព័ត៌មានលម្អិតពីផលិតផល ដែលលោក-លោកស្រី ចង់បញ្ជាទិញ។

**ដំណាក់កាលទី៣៖** លោក-លោកស្រី អាចជ្រើសរើសផលិតផលដែលចង់បញ្ជាទិញ រួចបំពេញចំនួនដែលចង់កុម្មង់ និងបំពេញព័ត៌មានបន្ថែមបន្តិចបន្តួចអំពីលោក-លោកស្រី ដើម្បីអាចឲ្យភាគីអ្នកលក់ផលិតផល (Merchant) បានទទួលព័ត៌មានអំពីលោក-លោកស្រី និង អាចទំនាក់ទំនងទៅកាន់លោក-លោកស្រីបាន ដើម្បីមកទទួលយកផលិតផលនៅថ្ងៃតាំងពិព័រណ៌។

**ដំណាក់កាលទី៤៖** ដើម្បីបញ្ជាក់ពីការបញ្ជាទិញ លោក-លោកស្រី តម្រូវឲ្យកក់ប្រាក់មួយចំនួនស្របតាមផលិតផលដែលបានកុម្មង់ ទៅតាមការកំណត់របស់ ភាគីអ្នកលក់ (Merchant) ដែលប្រាក់កក់នេះនឹងត្រូវបង់ចូលក្នុងគណនីធនាគាររបស់ KHB Events ដែលជាក្រុមហ៊ុនរៀបចំព្រឹត្តិការណ៍ពិព័រណ៌ **1st Phnom Penh Shopping Festival** នេះ ដើម្បីជាការបញ្ជាក់ពីការទិញ និងធានាពីសុវត្ថិភាពថវិការបស់លោក-លោកស្រី ខណៈលោក-លោកស្រី មិនទាន់ទទួលបានផលិតផលនៅឡើយ។

+855 60 815 515
+855 95 559 018
Building 2, level 5, Room No. 23A, No. 1159, National Road No.2 Chak Angre Leu Commune, Mean District Phnom Penh, Kingdom of Cambodia
www.khbevents.com

**ដំណាក់កាលទី៥៖** បន្ទាប់ពីការបង់ប្រាក់កក់រួចរាល់ លោក-លោកស្រី នឹងទទួលបានវិក្ក័យបត្រ **(Receipt)** មួយតាមតេឡេក្រាមបូត របស់ **Phnom Penh Shopping Festival** ដែលបញ្ជាក់ពីការកុម្មង់ផលិតផល និងថវិកាដែលបានបង់រួច ឈ្មោះហាងដែលបានបញ្ជាទិញ និងលេខស្តង់នៅក្នុងពិព័រណ៍។

**ដំណាក់កាលទី៦៖** ជាកិច្ចចុងក្រោយ លោក-លោកស្រី អាចមកទទួលយកផលិតផលនៅស្តង់ដែលបានកុម្មង់ ហើយបង់ថវិកាបង្គ្រប់ទៅកាន់គណនីធនាគាររបស់ KHB Events នៅក្នុងកម្មវិធីពិព័រណ៍ដោយផ្ទាល់ចាប់ពីថ្ងៃទី ២៦ ដល់ ២៧ កក្កដា ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និង ពិព័រណ៍កោះពេជ្រជាការស្រេច។

## II. ការបង់ប្រាក់បញ្ជាទិញ

២.១ ដើម្បីផ្តល់នូវការធានា និង ការការពារលើភាគីអ្នកលក់ និង អតិថិជនដែលបានបញ្ជាទិញ KHB Events ស្នើរអតិថិជនដែលបញ្ជាទិញទាំងឡាយ ឲ្យបង់ប្រាក់កក់ចេញពីការបញ្ជាទិញពីផ្សារអនឡាញទៅកាន់គណនីធនាគាររបស់ KHB Events ផ្ទាល់ ក្រោមឈ្មោះជាផ្លូវការ៖

- Account Name: KHB Media Co., Ltd.
- Account Number: 0001-05726299-99
- Bank Name: ACLEDA Bank Plc.

២.២ បន្ទាប់ពីលោក-លោកស្រី បានកក់ប្រាក់សម្រាប់ធានាដល់ការបញ្ជាទិញរួច លោក-លោកស្រី អាចបង់ប្រាក់បង្គ្រប់នៅថ្ងៃពិព័រណ៍ដោយផ្ទាល់ចាប់ពីថ្ងៃទី ២៦ ដល់ ២៧ ខែកក្កដា ឆ្នាំ២០២៥ ចាប់ពីម៉ោង ៩ព្រឹក ដល់ម៉ោង៩យប់ នៅមជ្ឈមណ្ឌលសន្និបាត និង ពិព័រណ៍កោះពេជ្រ។ នៅពេលដែលលោក-លោកស្រី បានមកដល់ស្តង់ដែលបានបញ្ជាទិញ នោះភាគីម្ចាស់ផលិតផលនឹងផ្ទៀងផ្ទាត់វិក្ក័យបត្រដែលលោក-លោកស្រី បានបញ្ជាទិញ ហើយបើឃើញថាត្រឹមត្រូវហើយ ពួកគេនឹងបង្ហាញ QR គណនីធនាគាររបស់ KHB Events ដើម្បីអោយ លោក-លោកស្រី ទូទាត់ប្រាក់បង្គ្រប់ រួចហើយនឹងប្រគល់ទំនិញលោក-លោកស្រី ជាការស្រេច។

## III. ការធានាលើការបញ្ជាទិញ

៣.១. ដើម្បីជាការធានាលើសុវត្ថិភាពថវិការបស់ លោក-លោកស្រី ប្រាក់កក់ដែលលោក-លោកស្រី បានបញ្ជាទិញតាមរយៈផ្សារអនឡាញរបស់ 1st Phnom Penh Shopping Festival នឹងមិនបាត់បង់នោះទេ ដរាបណាលោក-លោកស្រី រក្សាវិក្ក័យបត្របញ្ជាក់ពីការបញ្ជាទិញ ដែលបានផ្ញើរទៅលោក-លោកស្រី តាមរយៈតេឡេក្រាមបូត របស់ Phnom Penh Shopping Festival និងកំណត់ត្រាការទូទាត់តាមធនាគារ (Bank Transaction) ដែល លោក-លោកស្រី បានបង់ប្រាក់រួចរាល់ហើយ។

២. ប្រសិនបើលោក-លោកស្រី មិនបានទទួលទំនិញពីស្តង់ដែលបានបញ្ជាទិញដោយភាគីម្ចាស់ផលិតផល បដិសេធមិនបានទទួលការបញ្ជាទិញ ឬ ទំនិញអស់ពីស្តុកនោះ លោក-លោកស្រី អាចទាក់ទងមកកាន់ KHB Events ដើម្បីស្នើសុំថវិកាវិញ នោះ KHB Events នឹងត្រួតពិនិត្យរួចផ្ទេរថវិកាដែលបានកក់ទៅកាន់លោក-លោកស្រី ក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃនៃថ្ងៃធ្វើការ។

## IV. ករណីលោក-លោកស្រី ខកខានមិនបានមកយកទំនិញ

៤.១ ក្នុងករណី ដែលលោក-លោកស្រី ខកខានមិនបានមកទូទាត់ប្រាក់នៅសល់ និងមិនបានមកយកទំនិញនៅស្តង់ពិព័រណ៍ដោយផ្ទាល់នៅថ្ងៃទី ២៦ ដល់ ២៧ ខែកក្កដា ឆ្នាំ២០២៥ ទេនោះ មានន័យថា លោក-លោកស្រីបានបោះបង់ការបញ្ជាទិញផលិតផល

ដែលអ្នកបានកក់ប្រាក់ ហើយក្រុមហ៊ុន KHB Events សូមរក្សាសិទ្ធិមិនប្រគល់ប្រាក់កក់ជូន លោក-លោកស្រី វិញទេ បន្ទាប់ពីបញ្ចប់ពិព័រណ៍។

សេចក្តីដូចមានចែងនិងរៀបរាប់ខាងលើនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីដែលមានបំណងចង់សាកល្បងពិព័រណ៍ Offline/Online ដំបូងគេនៅកម្ពុជានេះនឹងចូលរួម អនុវត្តយ៉ាងម៉ឺងម៉ាត់បំផុតនូវ លក្ខខណ្ឌនិងការអនុវត្តនានា សម្រាប់បទពិសោធន៍ទិញទំនិញតាមពិព័រណ៍ Online នៅក្នុងព្រឹត្តិការណ៍ **1st Phnom Penh Shopping Festival** ខាងលើនេះ ដោយការយកចិត្តទុកដាក់ ដើម្បីធានាបាននូវសុវត្ថិភាព ភាពងាយស្រួល និងការសន្សំសំចៃ។

សូមលោក-លោកស្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥

ហត្ថលេខា និងត្រា




ទឹម វុត្ថា

អគ្គនាយក

ក្រុមហ៊ុន KHB Media Co., Ltd.